**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

លេខ ៧៤៧ ទ.ស.ក.ចស

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០១៦

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រឡងជ្រើសរើសបេក្ខជនឱ្យចូលបម្រើការងារ ក្នុងក្របខណ្ឌទីស្តីការគណៈរដ្ឋមន្ត្រី សម្រាប់ឆ្នាំ២០១៦

**យោង :** លិខិតលេខ៤៨៧ មស.ក្រ.ខ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦ របស់ក្រសួងមុខងារសាធារណៈ

ទីស្តីការគណៈរដ្ឋមន្ត្រី សូមជូនដំណឹងដល់និស្សិត និងមន្ត្រីរាជការទាំង ០២ភេទ ឱ្យបានជ្រាបថា សម្រាប់ឆ្នាំ២០១៦ នេះ ទីស្តីការគណៈរដ្ឋមន្ត្រីត្រូវការប្រឡងជ្រើសរើសមន្ត្រីក្របខណ្ឌថ្មី (ក្របខណ្ឌ "ក") ចំនួន ៧៣នាក់ លើមុខជំនាញនីតិសាស្ត្រ និងរដ្ឋបាលសាធារណៈ (៣៨នាក់) សេដ្ឋកិច្ច ហិរញ្ញវត្ថុ និងគណនេយ្យ (១៥នាក់) ទំនាក់ទំនងអន្តរជាតិ (១០នាក់) និងព័ត៌មានវិទ្យា (១០នាក់) ដើម្បីបម្រើការងារក្នុងក្របខណ្ឌទីស្តីការគណៈរដ្ឋមន្ត្រី។

**១. លក្ខខណ្ឌជ្រើសរើស**
- ត្រូវមានសញ្ជាតិខ្មែរ
- ត្រូវមានអាយុតិចជាង ៣០ឆ្នាំ ចំពោះនិស្សិត (កើតឆ្នាំ១៩៨៦ ឡើង) និងអាយុតិចជាង ៤៥ឆ្នាំ ចំពោះមន្ត្រីរាជការ (កើតឆ្នាំ១៩៧១ឡើង)
- ត្រូវមានសញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រសមមូលឡើងទៅ។

**២. វិញ្ញាសាប្រឡង :** មានវិញ្ញាសាសរសេរ និងវិញ្ញាសាផ្ទាល់មាត់

ក- វិញ្ញាសាសរសេរ
- វិញ្ញាសាចំណេះដឹងទូទៅ (រយៈពេល ០២ ម៉ោង)
- វិញ្ញាសាភាសាអង់គ្លេស (រយៈពេល ០១ ម៉ោង និង៣០ នាទី)
- វិញ្ញាសាជំនាញ (រយៈពេល ០២ ម៉ោង)

ខ- វិញ្ញាសាផ្ទាល់មាត់ សម្រាប់បេក្ខជនដែលប្រឡងជាប់វិញ្ញាសាសរសេរ។

**៣. កាលបរិច្ឆេទ និងមណ្ឌលប្រឡង**

ចំពោះកាលបរិច្ឆេទ និងមណ្ឌលប្រឡង នឹងជូនដំណឹងនៅពេលក្រោយ។

បេក្ខជនត្រូវបំពេញសំណុំលិខិត និងដាក់ពាក្យសុំចុះឈ្មោះប្រឡងនៅនាយកដ្ឋានបុគ្គលិក នៃទីស្តីការគណៈរដ្ឋមន្ត្រី (អគារថ្មី ជាន់ទី៤ តាមបណ្តោយផ្លូវកម្ពុជាក្រោម) រៀងរាល់ម៉ោងធ្វើការ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ រហូតដល់ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៦ វេលាម៉ោង ១៧:០០ នាទី។

**បញ្ជាក់** - បេក្ខជនជាជនពិការ និងស្ត្រី ដែលមានសមត្ថភាពសមស្រប ត្រូវបានផ្តល់ជាអាទិភាព។ ព័ត៌មានលម្អិត សូមទំនាក់ទំនងនៅនាយកដ្ឋានបុគ្គលិក រៀងរាល់ម៉ោងធ្វើការ និងតាមទូរសព្ទលេខ ០២៣ ២១២ ៣៤១។
- តម្លៃពាក្យសុំចុះឈ្មោះប្រឡង ៥,០០០ រៀល និងតម្លៃសុំសិទ្ធិប្រឡង ១០,០០០ រៀល។

អាស្រ័យហេតុនេះ សូមបេក្ខជនទាំងអស់ជ្រាបជាព័ត៌មាន។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មការប្រឡង**

**ប៊ុន អ៊ុយ**